ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១០១៣/១០៦០ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការផ្ទេរអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យាឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ២០អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញបទបញ្ជាលេខ០៥បប ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣ ស្តីពីការអនុវត្តព្រះរាជក្រឹត្យ និងអនុក្រឹត្យផ្ទេរ និងសមាហរណកម្មការងាររបស់ស្ថាប័នរដ្ឋមួយចំនួន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលបំណងដូចខាងក្រោម៖

- រៀបចំបេសកកម្ម និងរចនាសម្ព័ន្ធរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- រៀបចំមុខងារ និងភារកិច្ចរបស់អង្គភាពនានានៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ធានាគុណភាព និងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារក្នុងវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះគ្រប់អង្គភាពនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ទាំងអង្គភាពថ្នាក់កណ្តាល អង្គភាពស្វយ័ត អង្គភាពមូលដ្ឋាន ដោយគ្របដណ្តប់លើវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ទាំងថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ។

## ជំពូកទី ២
## បេសកកម្ម និងរចនាសម្ព័ន្ធ

**មាត្រា ៤.-**

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បំពេញមុខងារជាសេនាធិការឱ្យរាជរដ្ឋាភិបាលលើបេសកកម្មដឹកនាំ និងគ្រប់គ្រងវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជាក្នុងគោលដៅអភិវឌ្ឍសេដ្ឋកិច្ច និងលើកតម្កើងជីវភាពប្រជាជនដោយឈរលើគោលការណ៍សេដ្ឋកិច្ចទីផ្សារ និងសមធម៌សង្គម។

បេសកកម្មនេះត្រូវធ្វើឡើងតាមរយៈការរៀបចំ និងអនុវត្តន៍ឱ្យបានត្រឹមត្រូវនូវគោលនយោបាយច្បាប់ និងបទដ្ឋានទាំងឡាយដែលទាក់ទងនឹងវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៥.-**

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍មានមុខងារ និងភារកិច្ចដូចតទៅ៖

- រៀបចំ អនុវត្ត និងតាមដានការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការអភិវឌ្ឍវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- រៀបចំ អនុវត្ត និងតាមដានការអនុវត្តបទដ្ឋានគតិយុត្តសម្រាប់វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- រៀបចំគោលនយោបាយសម្របសម្រួល និងជំរុញការប្រកួតប្រជែងក្នុងការផ្តល់សេវាប្រៃសណីយ៍ និងទូរគមនាគមន៍
- រៀបចំគោលនយោបាយសម្រាប់ការប្រើប្រាស់សេវាសកល (USO) ក្នុងវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍
- រៀបចំគោលនយោបាយសម្រាប់ការផ្តល់អាជ្ញាប័ណ្ណ
- សហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីដឹកនាំ និងចូលរួមក្នុងការរៀបចំ អនុវត្តគោលនយោបាយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលលើកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និងកិច្ចការសមាហរណកម្មនៃព្រះរាជាណាចក្រកម្ពុជាចូលក្នុងក្របខ័ណ្ឌអនុតំបន់ តំបន់ សកលលោក និងអង្គការអន្តរជាតិ

- រៀបចំ និងជំរុញឱ្យការបង្កើតបណ្តាញ និងផ្តល់សេវាទូរគមនាគមន៍មានប្រសិទ្ធភាព សម្រាប់គ្រាអាសន្ន និងគ្រាមានគ្រោះមហន្តរាយក្នុងប្រទេស
- ធ្វើជាហត្ថលេខី និងជាតំណាងរាជរដ្ឋាភិបាលកម្ពុជាក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- កសាងគោលនយោបាយអភិវឌ្ឍធនធានមនុស្សសម្រាប់វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- បណ្តុះបណ្តាល និងធ្វើវិក្រឹត្យការជាប្រចាំនូវមុខជំនាញប្រៃសណីយ៍ និងទូរគមនាគមន៍ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- គ្រប់គ្រងស្តង់ដារវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- កសាងផែនការចំណូល ចំណាយហិរញ្ញវត្ថុ
- បំពេញមុខងារសវនកម្មផ្ទៃក្នុង
- ធ្វើអធិការកិច្ចលើការគ្រប់គ្រងវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

**មាត្រា ៦.-**

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍មានរចនាសម្ព័ន្ធដូចតទៅ៖

ក) អង្គភាពថ្នាក់កណ្តាល

-ខុទ្ទកាល័យរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានរដ្ឋបាល
- អគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍
- អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- អគ្គាធិការដ្ឋាន
- វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង

ខ) អង្គភាពស្វយ័ត

- បញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- សហគ្រាសសាធារណៈ៖
  +ទូរគមនាគមន៍កម្ពុជា
  +ប្រៃសណីយ៍កម្ពុជា

គ) អង្គភាពមូលដ្ឋាន

- មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្ត។

**មាត្រា ៧.-**

អគ្គនាយកដ្ឋានដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួនជាជំនួយការ។

អគ្គាធិការដ្ឋានដឹកនាំដោយអគ្គាធិការមួយរូប មានឋានៈស្មើអគ្គនាយក និងអមដោយអគ្គាធិការរងមួយចំនួនមានឋានៈស្មើអគ្គនាយករងជាជំនួយការ។

វិទ្យាស្ថានដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអគ្គនាយក និងអមដោយអនុប្រធានមួយចំនួន មានឋានៈស្មើអគ្គនាយករងជាជំនួយការ។

នាយកដ្ឋានដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

មជ្ឈមណ្ឌលដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងអមដោយ អនុប្រធានមួយចំនួន មានឋានៈស្មើអនុប្រធាននាយកដ្ឋានជាជំនួយការ។

អង្គភាពមូលដ្ឋាននៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនមានឋានៈចាប់ពីអនុប្រធាននាយកដ្ឋានចុះ។

អង្គការលេខរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៨.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន មជ្ឈមណ្ឌល និងអង្គភាពនានាក្រោមឱវាទរបស់អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន វិទ្យាស្ថាន និងអង្គភាពមូលដ្ឋាននៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

## ជំពូកទី ៣
## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា ៩.-**

ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មទាំងឡាយដែលកំណត់តាមបទប្បញ្ញត្តិក្នុងជំពូកទី ៦ នៃអនុក្រឹត្យលេខ២០អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន។

## ជំពូកទី ៤
## អគ្គនាយកដ្ឋានរដ្ឋបាល

**មាត្រា ១០.-**

អគ្គនាយកដ្ឋានរដ្ឋបាល បំពេញមុខងារជាសេនាធិការឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍លើបេសកកម្មគ្រប់គ្រងការងាររដ្ឋបាល ធនធានមនុស្ស ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង និងសម្របសម្រួលការងារទូទៅ ជាមួយបណ្តាក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល និងបណ្តាអង្គភាពមូលដ្ឋាន រាជធានី ខេត្ត។

**មាត្រា ១១.-**

អគ្គនាយកដ្ឋានរដ្ឋបាលមានភារកិច្ចដូចតទៅ៖

- ទទួលបន្ទុកគ្រប់គ្រងការងាររដ្ឋបាល
- លើកគម្រោងថវិកាក្រសួង ប្រមូលផ្តុំ និងសម្របសម្រួលជំពូកថវិកាបម្រើឱ្យរាល់ចំណាយរបស់ក្រសួង
- សិក្សា ស្រាវជ្រាវ និងសម្របសម្រួលរាល់សកម្មភាពរដ្ឋបាលជាមួយបណ្តាក្រសួង ស្ថាប័ន និងបណ្តាអង្គភាពមូលដ្ឋានរាជធានីខេត្ត ព្រមទាំងគ្រប់គ្រងការងារផែនការហិរញ្ញវត្ថុ សម្ភារៈបរិក្ខារ និងបញ្ជីសារពើភណ្ឌ
- ចូលរួមរៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
- ស្រាវជ្រាវ ចងក្រង និងផ្សព្វផ្សាយកម្រងលិខិតបទដ្ឋានគតិយុត្ត

- គ្រប់គ្រងបុគ្គលិក មន្ត្រីរាជការ ឯកសារ ការងារបណ្តុះបណ្តាលក្នុងក្របខ័ណ្ឌរបស់ក្រសួង ដោយទាក់ទងជាមួយអង្គភាពពាក់ព័ន្ធនៃក្រសួង ស្ថាប័ន
- វាយតម្លៃតម្រូវការបណ្តុះបណ្តាលបុគ្គលិក មន្ត្រីរាជការក្រសួង
- រៀបចំតួនាទី និងតំណែងឯកទេសរបស់ស្ថាប័ន និងធនធានមនុស្ស
- សិក្សា និងវាយតម្លៃតម្រូវការសម្រាប់កសាងឡើងវិញនូវសមត្ថភាពធនធានមនុស្ស និងបង្កើនគុណភាពវិជ្ជាជីវៈលើវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- បូកសរុបរបាយការណ៍ហិរញ្ញវត្ថុ និងសកម្មភាពការងាររបស់ក្រសួង
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ឱ្យ។

**មាត្រា ១២.-**

អគ្គនាយកដ្ឋានរដ្ឋបាលមាននាយកដ្ឋានចំណុះចំនួន០៣(បី)៖

- នាយកដ្ឋានរដ្ឋបាល
- នាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល
- នាយកដ្ឋានផែនការ និងហិរញ្ញវត្ថុ។

**មាត្រា ១៣.-**

នាយកដ្ឋានរដ្ឋបាល បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរដ្ឋបាលលើការសម្របសម្រួលការងារទូទៅរបស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាលជាមួយអង្គភាពមូលដ្ឋានក្រោមឱវាទ។

នាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរដ្ឋបាលលើការងារគ្រប់គ្រងបុគ្គលិក មន្ត្រីរាជការ និងការងារបណ្តុះបណ្តាល។

នាយកដ្ឋានផែនការ និងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរដ្ឋបាលលើការងារផែនការ និងហិរញ្ញវត្ថុ។

## ជំពូកទី ៥
## អគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍

**មាត្រា ១៤.-**

អគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍បំពេញមុខងារជាសេនាធិការឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍លើបេសកកម្មរៀបចំគោលនយោបាយ និងកសាងផែនការយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ និងចូលរួមសហការលើការងារប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគី អនុតំបន់ តំបន់ សកលលោក និងអង្គការអន្តរជាតិ។

**មាត្រា ១៥.-**

អគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍មានភារកិច្ចដូចតទៅ៖

- រៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍
- កសាងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍

- ចូលរួមសហការ និងសម្របសម្រួលការងារក្នុងវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រោមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគី អនុតំបន់ តំបន់ សកលលោក និងអង្គការអន្តរជាតិ
- រៀបចំ និងតាមដានការអនុវត្តគោលនយោបាយសម្រាប់ការប្រើប្រាស់សេវាសកល(USO) ក្នុងវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងគោលនយោបាយសម្រាប់រលកអាកាសវិទ្យុ(Frequency) និងប្រ៊ដប៊ែន(Broadband)ជាតិ
- គ្រប់គ្រងមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត
- ផ្តល់យោបល់ និងតាមដានការអនុវត្តការផ្តល់អាជ្ញាប័ណ្ណវិស័យប្រៃសណីយ៍
- រៀបចំ និងតាមដានការអនុវត្តគោលនយោបាយសម្រាប់ជំរុញការប្រកួតប្រជែង និងការការពារអ្នកប្រើប្រាស់វិស័យប្រៃសណីយ៍
- ចូលរួមរៀបចំគោលនយោបាយ និងផែនការអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- គ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា
- រៀបចំប្លង់លេខទូរស័ព្ទ និងលេខកូដប្រៃសណីយ៍
- ធ្វើរបាយការណ៍សកម្មភាពការងារជូនក្រសួង
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ឱ្យ។

**មាត្រា ១៦.-**

អគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍មាននាយកដ្ឋានចំណុះចំនួន០៤(បួន) និងមជ្ឈមណ្ឌលចំនួន ០១ (មួយ)៖

- នាយកដ្ឋានគោលនយោបាយទូរគមនាគមន៍
- នាយកដ្ឋានគោលនយោបាយប្រៃសណីយ៍
- នាយកដ្ឋានត្រួតពិនិត្យការគ្រប់គ្រងប្រៃសណីយ៍
- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
- មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា។

**មាត្រា ១៧.-**

នាយកដ្ឋានគោលនយោបាយទូរគមនាគមន៍ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍លើការងាររៀបចំគោលនយោបាយ និងកសាងផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការអភិវឌ្ឍវិស័យទូរគមនាគមន៍។

នាយកដ្ឋានគោលនយោបាយប្រៃសណីយ៍ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍លើការងាររៀបចំគោលនយោបាយ និងកសាងផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការអភិវឌ្ឍវិស័យប្រៃសណីយ៍។

នាយកដ្ឋានត្រួតពិនិត្យការគ្រប់គ្រងប្រៃសណីយ៍ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ លើការងារត្រួតពិនិត្យការគ្រប់គ្រងប្រៃសណីយ៍។

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ លើការងារសហប្រតិបត្តិការអន្តរជាតិពាក់ព័ន្ធនឹងវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍។

មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍លើការងារគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា។

## ជំពូកទី ៦
## អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

**មាត្រា ១៨.-**

អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ លើបេសកកម្មរៀបចំអនុវត្ត និងតាមដានការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាពអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ចូលរួមសហការលើការងារបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការអនុតំបន់ តំបន់ សកលលោក និងអង្គការអន្តរជាតិ និងកំណត់និយាមកម្មវិធីកុំព្យូទ័រ និងសន្តិសុខព័ត៌មានលើវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

**មាត្រា ១៩.-**

អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន មានភារកិច្ចដូចតទៅ៖

- រៀបចំ និងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាពអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- រៀបចំលិខិតបទដ្ឋានគតិយុត្តលើវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ចូលរួមសហការលើការងារបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការអនុតំបន់ តំបន់ សកលលោក និងអង្គការអន្តរជាតិ
- ចូលរួមរៀបចំ និងគ្រប់គ្រងប្រព័ន្ធសន្តិសុខព័ត៌មាន និងសុវត្ថិភាពបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- បង្កើតប្រព័ន្ធជូនដំណឹងជាមុនអំពីសន្តិសុខព័ត៌មាន
- រៀបចំដាក់ឲ្យដំណើរការមជ្ឈមណ្ឌលជាតិទទួលបន្ទុកការងារសន្តិសុខបច្ចេកវិទ្យាគមនា-គមន៍ និងព័ត៌មាន
- ស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗលើវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- រៀបចំ និងអភិវឌ្ឍសួនឧស្សាហកម្មវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- គ្រប់គ្រងផ្សព្វផ្សាយការប្រើប្រាស់កម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាននៅក្នុងវិស័យបច្ចេក-វិទ្យាគមនាគមន៍ និងព័ត៌មាន
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តចាំបាច់ និងកម្មវិធីកុំព្យូទ័រ
- គ្រប់គ្រង និងអភិវឌ្ឍប្រព័ន្ធការងារនៃរដ្ឋាភិបាលអេឡិកត្រូនិច
- គ្រប់គ្រងប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាល
- គ្រប់គ្រងប្រព័ន្ធ MIS និងWebsite របស់ក្រសួង
- អភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់ជនបទ
- ធ្វើរបាយការណ៍សកម្មភាពការងារជូនក្រសួង
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ឱ្យ។

**មាត្រា ២០.-**

អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានមាននាយកដ្ឋានចំណុះចំនួន០៧(ប្រាំពីរ)៖

- នាយកដ្ឋានរដ្ឋាភិបាលអេឡិកត្រូនិច
- នាយកដ្ឋានគោលនយោបាយបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- នាយកដ្ឋានគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ និងគ្រប់គ្រងប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាល
- នាយកដ្ឋានកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន

- នាយកដ្ឋានសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- នាយកដ្ឋានឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- នាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់ជនបទ។

**មាត្រា ២១.-**

នាយកដ្ឋានរដ្ឋាភិបាលអេឡិចត្រូនិច បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានលើការងារនៃរដ្ឋាភិបាលអេឡិចត្រូនិច។

នាយកដ្ឋានគោលនយោបាយបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានលើការងារគោលនយោបាយបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

នាយកដ្ឋានគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ និងគ្រប់គ្រងប្រព័ន្ធវិដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាល បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានលើការងារគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ និងគ្រប់គ្រងប្រព័ន្ធវិដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាល។

នាយកដ្ឋានកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានលើការងារកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន។

នាយកដ្ឋានសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានលើការងារសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

នាយកដ្ឋានឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានលើការងារឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

នាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់ជនបទ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានលើការងារបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់ជនបទ។

## ជំពូកទី ៧
## អគ្គាធិការដ្ឋាន

**មាត្រា ២២.-**

អគ្គាធិការដ្ឋានបំពេញមុខងារជាសេនាធិការឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍លើបេសកកម្មធ្វើអធិការកិច្ចជាប្រចាំលើការងារបច្ចេកទេស ការងាររដ្ឋបាល និងហិរញ្ញវត្ថុ ។

**មាត្រា ២៣.-**

អគ្គាធិការដ្ឋានមានភារកិច្ចដូចតទៅៈ

- ធ្វើអធិការកិច្ចទូទៅលើកិច្ចដំណើរការរដ្ឋបាលរបស់ក្រសួង អង្គភាពក្រោមឱវាទ និងកិច្ចដំណើរការរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ធ្វើអធិការកិច្ចរាល់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់អង្គភាពសាធារណៈ សហគ្រាសសាធារណៈ និងក្រុមហ៊ុនឯកជននានាដែលផ្តល់សេវាប្រៃសណីយ៍ និងទូរគមនាគមន៍ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ធ្វើការតាមដាន និងពង្រឹងការអនុវត្តច្បាប់ បទប្បញ្ញត្តិនានា លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដល់មន្ត្រីដែលកំពុងគ្រប់គ្រងលើវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានឱ្យទទួលខុសត្រូវតាមវិធានការវិន័យរដ្ឋបាល និងតុលាការ
- ចុះត្រួតពិនិត្យពាក្យបណ្តឹងតវ៉ា និងបណ្តឹងបរិហាររបស់ប្រជាពលរដ្ឋ សង្គមស៊ីវិលដែលទាក់ទងការគ្រប់គ្រងវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

- ធ្វើរបាយការណ៍សកម្មភាពការងារជូនក្រសួង
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ឱ្យ។

**មាត្រា ២៤.-**

អគ្គាធិការដ្ឋានមាននាយកដ្ឋានចំណុះចំនួន០៣(បី)៖

- នាយកដ្ឋានអធិការកិច្ចរដ្ឋបាល និងទទួលពាក្យបណ្ដឹង
- នាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុ
- នាយកដ្ឋានអធិការកិច្ចបច្ចេកទេស។

**មាត្រា ២៥.-**

នាយកដ្ឋានអធិការកិច្ចរដ្ឋបាល និងទទួលពាក្យបណ្ដឹង បំពេញមុខងារជាសេនាធិការឱ្យអគ្គាធិការដ្ឋានលើការងារអធិការកិច្ចរដ្ឋបាល និងទទួលពាក្យបណ្ដឹង។

នាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឱ្យអគ្គាធិការដ្ឋានលើការងារអធិការកិច្ចហិរញ្ញវត្ថុ។

នាយកដ្ឋានអធិការកិច្ចបច្ចេកទេស បំពេញមុខងារជាសេនាធិការឱ្យអគ្គាធិការដ្ឋានលើការងារអធិការកិច្ចបច្ចេកទេស។

## ជំពូកទី ៨
## វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

**មាត្រា ២៦.-**

វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍លើការងារអប់រំ បណ្ដុះបណ្ដាល ស្រាវជ្រាវ និងអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

**មាត្រា ២៧.-**

វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានមានភារកិច្ចដូចតទៅ៖

- រៀបចំកម្មវិធី អប់រំ និងបណ្ដុះបណ្ដាលវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- រៀបចំឱ្យមានការប្រឡងវាស់កម្រិតសមត្ថភាពជំនាញប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- លើកសំណើសុំចេញសញ្ញាប័ត្រ ឬវិញ្ញាបនប័ត្រទទួលស្គាល់កម្រិតសមត្ថភាពជំនាញលើវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- សហការជាមួយស្ថាប័នជាតិ និងអន្តរជាតិនានា ក៏ដូចវិស័យឯកជន ដើម្បីពង្រឹងការអប់រំ បណ្ដុះបណ្ដាល ស្រាវជ្រាវ និងផ្ទេរបច្ចេកវិទ្យាលើវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ស្រាវជ្រាវ និងអភិវឌ្ឍវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាគមនា-គមន៍ និងព័ត៌មាន
- ធ្វើរបាយការណ៍ស្ដីពីសកម្មភាពការងារជូនក្រសួង
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ឱ្យ។

**មាត្រា ២៨.-**

វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានមាននាយកដ្ឋានចំណុះចំនួន ៣ (បី) និងមជ្ឈមណ្ឌលចំណុះចំនួន០១ (មួយ)៖

- នាយកដ្ឋានប្រៃសណីយ៍
- នាយកដ្ឋានទូរគមនាគមន៍
- នាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍។

**មាត្រា ២៩.-**

នាយកដ្ឋានប្រៃសណីយ៍ បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានលើវិស័យប្រៃសណីយ៍។

នាយកដ្ឋានទូរគមនាគមន៍ បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានលើវិស័យទូរគមនាគមន៍។

នាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានជាតិប្រៃស-ណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានលើវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍ បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានលើការងារស្រាវជ្រាវ និងអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

## ជំពូកទី ៩
## នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**មាត្រា ៣០.-**

នាយកដ្ឋានសវនកម្មផ្ទៃក្នុង បំពេញមុខងារជាសេនាធិការឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ លើការងារពង្រឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

## ជំពូកទី ១០
## អង្គភាពមូលដ្ឋាន

**មាត្រា ៣១.-**

មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានលើការអនុវត្តសកម្មភាពនានារបស់ក្រសួង និងសម្របសម្រួលការងារជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី ១១
## បញ្ញត្តិករទូរគមនាគមន៍កម្ពុជា និងសហគ្រាសសាធារណៈ

**មាត្រា ៣២.-**

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍មាន៖

១) បញ្ញត្តិករទូរគមនាគមន៍កម្ពុជា ជានីតិបុគ្គលនៃនីតិសាធារណៈដែលបានទទួលសិទ្ធិពីរាជ-រដ្ឋាភិបាលមានស្វ័យភាពក្នុងការងារត្រួតពិនិត្យ និងគ្រប់គ្រងខាងផ្លូវបច្ចេកទេស និងរដ្ឋបាល

លើការស្ថាបនា ការធ្វើប្រតិបត្តិការ ការផ្តល់ និងការប្រើប្រាស់បណ្តាញ និងសេវាទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

២) សហគ្រាសសាធារណៈចំនួន០២៖

- សហគ្រាសសាធារណៈទូរគមនាគមន៍កម្ពុជា
- សហគ្រាសសាធារណៈប្រៃសណីយ៍កម្ពុជា។

សហគ្រាសសាធារណៈខាងលើនេះ មានលក្ខណៈជាក្រុមហ៊ុនរដ្ឋ ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី ១២
## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា ៣៣.-**

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុបង្កើតឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមលក្ខខណ្ឌនៃបទបញ្ញាកំណត់ក្នុងអនុក្រឹត្យលេខ៨១អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុងបណ្តាក្រសួង។

## ជំពូកទី ១៣
## អវសានប្បញ្ញត្តិ

**មាត្រា ៣៤.-**

ភារកិច្ចទាំងឡាយណាដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ស្ថាប័នដទៃ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍នឹងសហការជាមួយប្រធានស្ថាប័នពាក់ព័ន្ធ ដើម្បីបែងចែកការទទួលខុសត្រូវ និងអនុវត្តការងារតាមរយៈប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍និងប្រធានស្ថាប័ននោះ។

**មាត្រា ៣៥.-**

អនុក្រឹត្យនេះត្រូវជំនួសអនុក្រឹត្យដូចខាងក្រោម៖

- អនុក្រឹត្យលេខ៦៦អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- អនុក្រឹត្យលេខ៨៦អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០២ ស្តីពីការកែសម្រួល និងបំពេញបន្ថែមនាយកដ្ឋានមួយចំនួននៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អនុក្រឹត្យលេខ០៥អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៣ ស្តីពីការដំឡើងនាយកដ្ឋានរដ្ឋបាល និងបណ្តុះបណ្តាលទៅជាអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគន៍
- អនុក្រឹត្យលេខ៨២អនក្រ.បក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការដំឡើងការិយាល័យអាស៊ាន និងអង្គភាពពាណិជ្ជកម្មពិភពលោកទៅជានាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អនុក្រឹត្យលេខ១៣អនក្រ.បក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អនុក្រឹត្យលេខ១៣៥អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការបង្កើតមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យានៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- អនុក្រឹត្យលេខ ១៨១អនក្រ.បក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការដំឡើងអធិការដ្ឋានទៅជាអគ្គាធិការដ្ឋាននៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

**មាត្រា ៣៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

**ប្រាក់ សុខុន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ